# NATIVE LANGUAGE LITERACY SCREENING DEVICE (KHMER)

ចំពោះកូនសិស្ស:

សាលារៀនយើង សូមស្វាគមន៍

ចម្លើយក្នុងលិខិតនេះ នឹងអាចជួយឲ្យយើងជ្រើសរើសយកមុខវិជ្ជាដ៏ល្អមួយដល់អ្នក
ដើម្បីចាប់ផ្តើមកម្មវិធីនេះ។

សូមឆ្លើយបំពេញលិខិតនេះ ដោយខ្លួនឯង

ប្រសិនបើអ្នកមិនអាចឆ្លើយ ទៅគ្រប់សំនួរទាំងអស់នេះបានទេនោះ, សូមឆ្លើយតែសំនួរ ណាដែលអាចឆ្លើយបាន
ហើយសំនួរដទៃទៀតទុកចោលចុះ។

សូមអរគុណ

ថ្ងៃនេះ ទី: __________________

ឈ្មោះ: __________________

អសយដ្ឋាន: __________________

ទូរស័ព្ទ: __________________

ថ្ងៃ ខែឆ្នាំ កំណើត: __________________

១. តើអ្នកកើតនៅឯណា?

________________________________________

២. តើអ្នកមកដល់សហរដ្ឋអាមេរិក កាលពីឆ្នាំណា?

________________________________________

៣. នៅប្រទេសអ្នក តើអ្នករៀននៅសាលា បានប៉ុន្មានឆ្នាំដែរ?

________________________________________

៤. តាំងពីមកដល់ សហរដ្ឋអាមេរិក តើអ្នកធ្លាប់បានរៀនភាសា
អង់គ្លេសនៅតាមសាលារៀន ដែរឬទេ?

________________________________________

៥. តើអ្នកបានរៀបការ ឬទេ?

________________________________________

៦. តើអ្នកមានកូន ឬទេ?

________________________________________

៧. នៅផ្ទះរបស់អ្នក តើអ្នកនិយាយភាសាអ្វីដែរ?

---------------------------------------

៨. តើអ្នកធ្លាប់អាន សារពត៌មាន ឬទស្សនាវដ្ដី ភាសាខ្មែរឬទេ?

---------------------------------------

៩. តើអ្នកប្រកបមុខរបរ ផ្នែកខាងអ្វីដែរ?

---------------------------------------

១០. នៅពេលទំនេរ តើអ្នកចូលចិត្តធ្វើអ្វីដែរ?

---------------------------------------

**សូមអរគុណ នៃការឆ្លើយនូវសំនួរទាំងអស់នេះ**

---------------------------------------

នៅទំព័របន្ទាប់នេះ គឺជារឿងខ្លះៗ របស់កូនសិស្សដទៃទៀត
ដែលបានមកចូលសាលារៀន ដើម្បីរៀនភាសាអង់គ្លេស។

សូមអានរឿងទាំងអស់នោះ។

**រឿងទី១.**

ខ្ញុំសប្បាយចិត្ត
ខ្ញុំមានអារម្មណ៍ថា ខ្ញុំកំពុងតែរៀន
ខ្ញុំកំពុងតែរៀននិយាយ ភាសាអង់គ្លេស
ខ្ញុំកំពុងតែ ចាប់ផ្តើមកសាងជីវិតថ្មី នៅក្នុងប្រទេសនេះ
នៅក្នុងសាលារៀន មានសិស្សរួមថ្នាក់ខ្ញុំ និងគ្រូខ្ញុំ ជាអ្នកជួយដល់ការសិក្សារបស់ខ្ញុំ។

---

**រឿងទី២.**

កូនប្រុសខ្ញុំ ចេះនិយាយភាសាអង់គ្លេស
គាត់និយាយភាសា អង់គ្លេសជាមួយ មិត្តភ័ក្ររបស់គាត់
ខ្ញុំនិយាយទៅកាន់គាត់ ជាភាសាខ្មែរ
គាត់និយាយមករកខ្ញុំ ជាភាសាអង់គ្លេស
ខ្ញុំមានការពិបាកណាស់ ក្នុងការនិយាយភាសាអង់គ្លេស
ដូច្នេះ ឥឡូវនេះ ខ្ញុំមកសាលារៀននេះ ដើម្បីរៀនភាសាអង់គ្លេស។

រឿងទី៣.

ខ្ញុំបានមកដល់សហរដ្ឋអាមេរិក ក្នុងឆ្នាំ១៩៨២ ។

ខ្ញុំមកសាលាបង្រៀន មនុស្សពេញវ័យនេះ, ព្រោះខ្ញុំចង់រៀនភាសាអង់គ្លេស។ មកសាលារៀន នៅថ្ងៃមុនគំបូង, ខ្ញុំមានការជ្រួលច្រាលក្នុងចិត្តណាស់។

កាលខ្ញុំនៅពីក្មេង, ខ្ញុំមិនអាចទៅសាលារៀនបានទេ, ព្រោះខ្ញុំត្រូវធ្វើការ ជួយដល់គ្រួសារខ្ញុំ។

នៅថ្ងៃមុនគំបូងដែលខ្ញុំមកសាលាបង្រៀនមនុស្សពេញវ័យនេះ, ខ្ញុំមិនដឹងថា តើនឹងមានសភាពបែបណាទេ។ ប៉ុន្តែគ្រូរបស់ខ្ញុំគាត់ចិត្តល្អណាស់, ហើយចំណែក កូនសិស្សផ្សេងទៀត ក៏ចិត្តល្អដែរ។ ឥឡូវនេះ ខ្ញុំលែងមានការភ្ញាក់ផ្អើលហើយ។

---

រឿងទី៥.

ខ្ញុំមានអាយុ២៥ឆ្នាំ, ខ្ញុំមានកូនស្រីពីរនាក់។ ខ្ញុំមកសហរដ្ឋអាមេរិកនេះ, ព្រោះខ្ញុំចង់ បានជីវភាពរស់នៅឲ្យបានល្អសម្រាប់កូនស្រីខ្ញុំ, ខ្ញុំចង់បានការងារដ៏ល្អមួយ។

ឥឡូវនេះ ខ្ញុំមកសាលាបង្រៀនមនុស្សពេញវ័យនេះ។ យើងបានសាកល្បងនិយាយ ភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន។ ខ្ញុំបានសាកនិយាយភាសាអង់គ្លេសនៅផ្ទះ ប៉ុន្តែ មិនមែនជាការស្រួលទេ។ មិត្តភ័ក្រខ្ញុំនិយាយភាសាខ្មែរទាំងអស់គ្នា។ ពេលខ្លះខ្ញុំមើល កម្មវិធីទូរទស្សន៍ ដែលផ្សាយជាភាសាអង់គ្លេស។

ឆ្លៀតពេលមកសាលារៀន មិនមែនជាការងាយស្រួលទេ។ តែខ្ញុំធ្វើនេះ គឺសម្រាប់ ប្រយោជន៍ដល់កូនស្រីរបស់ខ្ញុំ។

យើងសង្ឃឹមថា អ្នកនឹងចូលចិត្តចំពោះរឿងរបស់កូនសិស្ស ដែលបានមករៀនភាសាអង់គ្លេស នៅក្នុងសាលារៀននេះ។

នៅពីលើបន្ទាត់ខាងក្រោមនេះ, សូមសរសេររឿងរបស់អ្នក។ សូមប្រាប់យើងថា ហេតុអ្វីបានជាអ្នកចង់រៀនភាសាអង់គ្លេស, ឬក៏រឿងអ្វីផ្សេងទៀត ដែលអ្នកចង់ប្រាប់យើង។